## ព្រឹត្តិបត្របច្ចេកទេស លេខ ៧៣

# ការបណ្តុះ និងថែរក្សាថ្នាលបណ្តុះកូនឈើ

ការបណ្តុះគ្រាប់ពូជអាចអនុវត្តតាមវិធីសាស្ត្រច្រើនយ៉ាង អាស្រ័យទៅលើប្រភេទនៃគ្រាប់ពូជ ថាតើវាអាចរក្សាទុកបានយូរ ឬរហ័សងាយឆាប់ខូច ។ ការបណ្តុះគ្រាប់ពូជក៏អាស្រ័យផងដែរទៅតាមល័ក្ខណ្ឌមួយចំនួនទៀត ដូចជា៖ សំបកក្រាស់ សំបករឹង ។ល។



ពពួកគ្រាប់ស្ងួត (រូបភាពទី១)

រូបភាពទី ១



ពពួកគ្រាប់ឆាប់ខូច(រូបទី ២)

រូបភាពទី ២

## ប្រព្រឹត្តិកម្មគ្រាប់ពូជ

ហាលគ្រាប់ពូជក្រោមពន្លឺថ្ងៃ (រូបភាពទី៣) ។



រូបភាពទី ៣



រូបភាពទី ៤

ប្រព្រឹត្តិកម្មគ្រាប់ពូជអាចអនុវត្តបានតាមវិធីសាស្ត្រផ្សេងៗគ្នា ។ ប្រភេទគ្រាប់ពូជមួយចំនួនត្រូវការ ឆាប ឬ ច្រឹបសំបកចេញបន្តិច មុននឹងត្រាំទឹក (រូបភាពទី៤) ។

បន្ទាប់មក ត្រូវយកគ្រាប់ពូជដែលឆាប ឬ ច្រឹបរួច ទៅត្រាំទឹកត្រជាក់ចំនួន ១-២ ថ្ងៃ (អាស្រ័យទៅតាមភាពក្រាស់នៃសំបកគ្រាប់) ឬ ត្រាំក្នុងទឹកក្តៅ (70-80 អង្សាសេ) ក្នុងរយៈពេល ១-២ នាទី (រូបភាពទី៥) ។



រូបភាពទី ៥

ក្រោយពេលត្រាំក្នុងទឹករួច ត្រូវលាងសម្អាត និងរក្សាគ្រាប់ពូជនៅក្នុងបាវ ឬ ក្រណាត់សើម (រូបភាពទី៦) ។



រូបភាពទី ៦



រូបភាពទី ៧

ត្រូតពិនិត្យ និង លាងគ្រាប់ពូជជារៀងរាល់ថ្ងៃ ហើយរក្សាសំណើមរាល់ពេលវេលា រហូតដល់គ្រាប់ចេញពន្លកឬស រួចយកគ្រាប់ដែលដុះពន្លកទៅដាំនៅក្នុងថង់ ឬ សាបនៅក្នុងថ្នាល (រូបភាពទី ៧) ។

ត្រូវពិនិត្យគ្រាប់ពូជដែលបានធ្វើប្រព្រឹត្តិកម្មអោយបានទៀងទាត់ ហើយស្ទូងគ្រាប់ពូជណាដែលចេញពន្លកឬសនៅក្នុងថង់ភ្លាម ដើម្បីការពារកុំអោយឬសដុះវែងទាន់ (រូបភាពទី ៨)។




រូបភាពទី ៨

**កម្ពុជាហាវេស**

ផ្ទះលេខ ៤៦ ផ្លូវ ៣១០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
ក្រុងភ្នំពេញ
ទូរស័ព្ទ ០២៣ ៩៩៦ ៤១៩
harvest@fintrac.com

ព្រឹត្តិបត្រនេះរៀបចំឡើងក្រោមការឧបត្ថម្ភពីប្រជាពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID)។

ខ្លឹមសារនៅក្នុងឯកសារនេះគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុន ហ្វីនត្រាក់ Fintrac Inc. និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬ រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។